# ផ្លូវចូលទៅចាក់វ៉ាក់សាំងនៅទីតាំងដៃគូរបស់ King County

ធ្វើបច្ចុប្បន្នភាពថ្ងៃទី 25 ខែមីនាឆ្នាំ 2021

សម្រាប់ព័ត៌មានបន្ថែមអំពីទីតាំងទាំងនេះឬវិធីដាក់ណាត់ជួប សូមចូលទៅគេហទំព័រ ការទទួលចាក់វ៉ាក់សាំងនៅក្នុងតំបន់យើងខោនធី King County ឬទូរស័ព្ទទៅមណ្ឌលទទួលបន្ទុកជំងឺកូវីដ-១៩ របស់រដ្ឋវ៉ាស៊ីនតោនតាមរយៈលេខ៖ 1-800-525-0127 ឬ 1-888-856-5816 (បន្ទាប់មកចុចសញ្ញា # ) នៅថ្ងៃច័ន្ទ ម៉ោង 6 ព្រឹក - 10 យប់ ថ្ងៃអង្គារ - អាទិត្យពីម៉ោង 6 ព្រឹក - 6 ល្ងាច។ សម្រាប់ការបកប្រែភាសា សូមនិយាយប្រាប់ភាសាដែលអ្នកនិយាយនៅពេលគេភ្ជាប់ទូរស័ព្ទ។

## ទីតាំងនៅ Auburn

- មានផ្លូវសម្រាប់អោយអ្នកពិការចេញចូលបាន។
- មានបកប្រែភាសាគ និងភាសានិយាយនៅនឹងកន្លែង។
- ប្រសិនបើត្រូវការសេវាកម្មបកប្រែសម្រាប់មនុស្សខ្វាក់ សូមទាក់ទងទៅមណ្ឌលផ្តល់សេវាកម្មសម្រាប់មនុស្សថ្លង់/ខ្វាក់របស់ទីក្រុងស៊ីអាថល៖ http://seattledbsc.org (គេហទំព័រមានតែជាភាសាអង់គ្លេសប៉ុណ្ណោះ)

## ទីតាំងនៅ Kent

- មានផ្លូវសម្រាប់អោយអ្នកពិការចេញចូលបាននិងមានរទេះសម្រាប់រុញអ្នកពិការ។
- មានបកប្រែភាសាគ និងភាសានិយាយនៅនឹងកន្លែង។
- ប្រសិនបើត្រូវការសេវាកម្មបកប្រែសម្រាប់មនុស្សខ្វាក់ សូមទាក់ទងទៅមណ្ឌលផ្តល់សេវាកម្មសម្រាប់មនុស្សថ្លង់/ខ្វាក់របស់ទីក្រុងស៊ីអាថល៖ http://seattledbsc.org (គេហទំព័រមានតែជាភាសាអង់គ្លេសប៉ុណ្ណោះ)

## ទីតាំងនៅ Renton

- គ្រប់មន្ទីរចាក់វ៉ាក់សាំងទាំងអស់គឺមានផ្លូវសម្រាប់អោយអ្នកពិការចេញចូលបាននិងមានរទេះសម្រាប់រុញអ្នកពិការ។
- នៅពេលអ្នកមកដល់ មានសេវាកម្មបកប្រែភាសាតាមរយៈវីឌីអូ (VRI) ជូនមនុស្សគ ថ្លង់ ឬបកប្រែភាសានិយាយ។
- ប្រសិនបើត្រូវការសេវាកម្មបកប្រែសម្រាប់មនុស្សខ្វាក់ សូមទាក់ទងទៅមណ្ឌលផ្តល់សេវាកម្មសម្រាប់មនុស្សថ្លង់/ខ្វាក់របស់ទីក្រុងស៊ីអាថល៖៖ http://seattledbsc.org (គេហទំព័រមានតែជាភាសាអង់គ្លេសប៉ុណ្ណោះ)

## ទីតាំងនៅ Redmond

- នៅពេលអ្នកទូរស័ព្ទមកដាក់ណាត់ជួបជាមួយទីតាំងនៅ Redmond អ្នកអាចស្នើសុំសេវាកម្មបកប្រែភាសា។
- ទីតាំងនេះមានផ្លូវសម្រាប់អ្នកពិការចេញចូលបាននិងមានបុគ្គលិកជំនាញដើម្បីជួយអ្នក។ មានរទេះសម្រាប់រុញអ្នកពិការតាមសំណូមពរ។
- ប្រសិនបើអ្នកចតរថយន្តនៅចំណតក្រោមដី អ្នកនឹងត្រូវដើរចម្ងាយខ្លីទៅជណ្តើរយន្តដែល នឹងនាំអ្នកទៅកាន់ច្រកចូលទៅមន្ទីរសុខភាព។ ឬគេអាចដាក់អ្នកអោយចុះនៅចំមុខច្រកចូលតែម្តង។
- នៅពេលអ្នកមកដល់ មានសេវាកម្មបកប្រែពេទ្យតាមទូរស័ព្ទនិងតាមអនឡាញជាង ២០០ ភាសា រួមមានអ្នកបកប្រែភាសានៅនិងកន្លែងផ្ទាល់ ដូចជា ភាសាអេស្ប៉ាញ ចិនកុកងឺ ហិណ្ឌូ និងភាសាគ ថ្លង់។
- មានសម្ភារៈនិងផ្លាកសញ្ញាដែលបានបោះពុម្ពជាច្រើនភាសានៅនិងកន្លែង។

- ប្រសិនបើអ្នកត្រូវការសេវាកម្មបកប្រែសម្រាប់មនុស្សខ្វាក់ សូមទាក់ទងទៅមណ្ឌលផ្តល់សេវាកម្មសម្រាប់មនុស្សថ្លង់ / ខ្វាក់របស់ទីក្រុងស៊ីអាថល៖ http://seattledbsc.org (គេហទំព័រមានតែជាភាសាអង់គ្លេសប៉ុណ្ណោះ)

## ទីតាំងនៅ Rainier Beach និង West Seattle

- នៅពេលអ្នកទៅដល់ ទីតាំងទាំងពីរមានផ្លូវសម្រាប់អោយអ្នកពិការចូលទៅកន្លែងចាក់វ៉ាក់សាំង។
- ប្រសិនបើអ្នកមិនអាចចេញពីក្នុងឡានរបស់អ្នកទេ បុគ្គលិកអាចចុះឈ្មោះអ្នកហើយចាក់វ៉ាក់សាំងឲ្យអ្នកនៅពេលអ្នកកំពុងនៅក្នុងឡានរបស់អ្នក។
- ទីតាំងទាំងអស់មានសេវាកម្មបកប្រែភាសានិងសេវាកម្មបកប្រែភាសាគ ថ្លង់ តាមរយៈវីឌីអូ។
- ប្រសិនបើអ្នកត្រូវការសេវាកម្មបកប្រែសម្រាប់មនុស្សខ្វាក់ សូមទាក់ទងទៅមណ្ឌលផ្តល់សេវាកម្មសម្រាប់មនុស្សថ្លង់ / ខ្វាក់របស់ទីក្រុងស៊ីអាថល៖ http://seattledbsc.org (គេហទំព័រមានតែជាភាសាអង់គ្លេសប៉ុណ្ណោះ)

## ទីតាំងនៅ Lumen Field, ទីក្រុងស៊ីអាថល

- គ្រប់ច្រកចូលទាំងអស់នៅមជ្ឈមណ្ឌល Lumen Field  គឺមានផ្លូវសម្រាប់អោយអ្នកពិការចេញចូលបាន។
- ប្រសិនបើអ្នកមកដល់ដោយរថយន្ត ច្រកធំសម្រាប់អោយអ្នកពិការចេញចូលគឺច្រកដែល ស្ថិតនៅជិតចំណតរថយន្តរបស់មជ្ឈមណ្ឌល Lumen Field ដែលមានទីតាំងស្ថិតនៅ 330 S Royal Brougham Way ។
- គេនឹងមានជំនួយដឹកជញ្ជូននៅពេលអ្នកចូលមកដល់ខាងក្នុងអគារ។ សូមចូលតាមខ្សែបន្ទាត់ ដែលសរសេរថា 'Line A' ហើយពេលនោះគេនឹងជួយអ្នក។
- មានសេវាកម្មបកប្រែភាសានៅនិងកន្លែងជាង 200 ភាសា។ សូមចូលតាមខ្សែបន្ទាត់ដែលសរសេរថា 'Line B 'ហើយពេលនោះគេនឹងជួយអ្នក។
- ប្រសិនបើអ្នកត្រូវការសេវាកម្មបកប្រែសម្រាប់មនុស្សខ្វាក់ សូមទាក់ទងទៅមណ្ឌលផ្តល់សេវាកម្មសម្រាប់មនុស្សថ្លង់ / ខ្វាក់របស់ទីក្រុងស៊ីអាថល៖ http://seattledbsc.org (គេហទំព័រមានតែជាភាសាអង់គ្លេសប៉ុណ្ណោះ)